រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

038KH01A-01

ការជួយសម្រាលទុក្ខអ្នកជំងឺ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៣៨

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™



មូលហេតុដែលនាំអោយមានទុក្ខលំបាក និង របៀបដែលព្រះជាម្ចាស់ប្រើទុក្ខលំបាក ដើម្បីជាប្រយោជន៍ដល់យើង

យើងនាំគ្នាមើលពីសេចក្តីពិតអំពីបញ្ហាទាំងពីរនេះ ដែលសៀវភៅយ៉ូបបង្រៀន និង ពន្យល់ដល់យើង ។

« កាលពីដើម នៅស្រុកអ៊ូស មានបុរសម្នាក់ឈ្មោះយ៉ូប ជាមនុស្សទៀងត្រង់ និង សុចរិត ។ លោកគោរពកោតខ្លាចព្រះជាម្ចាស់ ហើយចៀសវាងប្រព្រឹត្តអំពើអាក្រក់ » (យ៉ូប ១:១) ។

បើតាមការយល់ឃើញរបស់អ្នក តើលោកយ៉ូបត្រូវទទួលទណ្ឌកម្មដែរឬទេ ? ។ _____

_____

កំណត់ចំណាំ :

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

_____

© Project WorldReach © SEAN

កំណត់ចំណាំ :

ហេតុអ្វីបានជាអ្នកថាដូចនេះ ? ។

ប៉ុន្តែ លោកយ៉ូបរងទុក្ខលំបាកខ្លាំងណាស់ ។ ទោះបីជាគាត់ជាមនុស្សទៀងត្រង់ និង ពោរពេញដោយជំនឿក៏ដោយ ក៏គាត់បាត់បង់អ្វីៗ ដែលជាទីស្រឡាញ់របស់គាត់ទាំងអស់ គឺកូនប្រុសកូនស្រី របស់គាត់ទាំងប៉ុន្មាន ហ្វូងសត្វ បាវបំរើ ទ្រព្យសម្បត្តិ ហើយមារសាតាំងធ្វើអោយគាត់ឈឺចាប់ ដោយសារមានដំបៅរីកពេញខ្លួនទៀត (យ៉ូប ១:១៣-១៩, ២:៤-៧) ។



ប្រពន្ធរបស់យ៉ូបជំរុញអោយយ៉ូបផ្តាក់ល្បែង ដោយនិយាយថា÷



កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ទន្ទេញ ២ កូរិនថូស ១:៣-៤ ។
- សូមណែនាំប្រមូលក្រុមជំនុំរបស់អ្នក អោយជួយសំរាលទុក្ខ និង អធិស្ឋានសំរាប់អ្នកជំងឺ ដោយប្រើអត្ថបទសិក្សានេះ ។
- សូមសរសេរឈ្មោះអ្នកជំងឺ ដែលអ្នកត្រូវទៅសួរសុខទុក្ខ ។

លោកយ៉ូបមិនបានដឹងថា មារសាតាំងធ្វើអោយគាត់ឈឺចាប់ទេ ។ តែទោះបីជាគាត់រងទុក្ខលំបាកយ៉ាងណាក៏ដោយ ក៏គាត់នៅតែថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់ដែរ ។

- ហេតុអ្វីបានជាលោកយ៉ូប ដែលជាមនុស្សល្អ គ្មានកំហុស និង សុចរិត ទៅជាមានជំងឺទៅវិញ ?
- ហេតុអ្វីបានជាគាត់បាត់បង់គ្រួសារ និង ទ្រព្យសម្បត្តិរបស់គាត់ ?
- ហេតុអ្វីបានជាសព្វថៃនេះ ពួកគ្រីស្តជន និង ក្មេងៗដែលគ្មានកំហុសត្រូវរងទុក្ខលំបាក ?
- ហេតុអ្វីបានជាយើងមានជំងឺ និង ចាស់ទៅៗ ?
- ហេតុអ្វីបានជាព្រះជាម្ចាស់ទុកអោយយើងមានទុក្ខលំបាក ? ។

សំនួរទាំងប៉ុន្មាននេះ ធ្វើអោយមនុស្សងឿងឆ្ងល់ជាយូរណាស់មកហើយ ។

ជួនកាល ព្រះជាម្ចាស់បណ្តោយអោយមានជំងឺ ដើម្បីស្តង់មើលជំនឿរបស់យើង ។

អានយ៉ូប ១:២០-២២ និង ២:៩-១០ ។ នៅក្នុងវគ្គនេះ យើងឃើញសេចក្តីពិតសំខាន់ៗពីរយ៉ាង គឺ :

- មារសាតាំងបណ្តាលអោយមានជំងឺ ។
- ពេលខ្លះព្រះជាម្ចាស់ទុកអោយយើងមានទុក្ខលំបាក ដើម្បីស្តង់មើលពីជំនឿរបស់យើង ។

តើហេតុអ្វីបានជាយ៉ូបត្រូវរងទុក្ខលំបាក ?

☐ គាត់រងទុក្ខលំបាក ដែលជាទោសនៃអំពើបាបរបស់គាត់ ។

☐ ព្រះជាម្ចាស់អនុញ្ញាតិអោយមារសាតាំង ធ្វើដូចនេះ ដើម្បីស្តង់មើលពីជំនឿរបស់យ៉ូប ។

រឿងនេះបញ្ចប់ដោយហេតុការណ៍ល្អ ។ ព្រះជាម្ចាស់ប្រោសលោកយ៉ូបអោយជា ហើយប្រទានពរគាត់អោយមានអ្វីៗទ្វេមួយជាពីរលើសអ្វីៗដែលគាត់ធ្លាប់មានពីមុនមក ។

៣- ឧបមាថា ព្រះវិញ្ញាណដ៏វិសុទ្ធបើកសំដែងប្រាប់អ្នកថា អ្នកជំងឺម្នាក់បានអនុញ្ញាតិឱ្យវិញ្ញាណអារក្សគ្រប់គ្រងលើគាត់ ។ តើអ្នកត្រូវអធិស្ឋានដូចម្តេច ? ។

_____

_____

_____

_____

_____

៤- ឧបមាថា អ្នកទៅសួរសុខទុក្ខមនុស្ស ដែលឈឺខ្លាំងម្នាក់ ហើយដែលអ្នកមិនធ្លាប់ស្គាល់ ។ អ្នកនោះពិបាកនិយាយ ទើបអ្នកមិនដឹងពីមូលហេតុ ដែលនាំឱ្យគាត់មានបញ្ហា ឬមិនដឹងពីសភាពព្រលឹងវិញ្ញាណរបស់គាត់ ។ តើអ្នកត្រូវធ្វើដូចម្តេច ? ។

_____

_____

_____

_____

© Project WorldReach © SEAN

១- ឧបមាថា អ្នកទៅសួរសុខទុក្ខបងប្អូនម្នាក់ ដែលមានជំងឺដោយសារការធ្វេសប្រហែសរបស់ខ្លួនគាត់ផ្ទាល់ ។ តើអ្នកត្រូវណែនាំគាត់ដូចម្តេច ? ។

_____

_____

_____

_____

_____

២- ឧបមាថា អ្នកកំពុងជូនយោបល់ប្រាប់អ្នកជឿស្មោះត្រង់ចាស់ម្នាក់ ដែលជិតស្លាប់ហើយ ។ តើអ្នកនឹងនិយាយលួងលោមគាត់ដូចម្តេច ? ។

_____

_____

_____

_____

_____

_____

សូមអាន កំណើតពិភពលោក ៣:១-២១ ។ តាមរយៈខគម្ពីរនេះ យើងឃើញថា អ្វីៗគ្រប់យ៉ាង ដែលព្រះជាម្ចាស់បានបង្កើតត្រូវប្រែប្រួល ដោយសារអំពើបាបបានចូលមកក្នុងពិភពលោក ។ លទ្ធផលនៃអំពើបាបទាំងនោះ គឺភាពសត្រូវនឹងគ្នា របួស ការឈឺចាប់ ការគាបសង្កត់ បញ្ហាស្មុគស្មាញ ទុក្ខលំបាក ។ល។ ។

ដូច្នេះ យើងឃើញថា :

- មារសាតាំងចាប់មនុស្សធ្វើជាទាសករ (ហេប្រឺ ២:១៥) ។
- ទុក្ខលំបាក និង សេចក្តីស្លាប់បានចូលមកក្នុងពិភពលោក តាមរយៈអំពើបាបរបស់លោកអាដាម (រ៉ូម ៥:១២, កំណើតពិភពលោក ៣:១៤-១៩) ។
- ជួនកាល ព្រះជាម្ចាស់ទុកអោយយើងមានទុក្ខលំបាក ដើម្បីស្ទង់មើលជំនឿរបស់យើង និង ដឹកនាំយើងអោយស្វែងរកព្រះអង្គ ។

ជួនកាល ព្រះជាម្ចាស់បង្ហាញសិរីរុងរឿងរបស់ព្រះអង្គ តាមរយៈជំងឺ ។

សូមអានយ៉ូហាន ៩:១-២ ។ វគ្គព្រះគម្ពីរនេះ និយាយអំពីបុរសម្នាក់ដែលខ្វាក់ពីកំណើត ។ គាត់ជាមនុស្សពិការភ្នែក ។ ដូចដែលយើងបាននិយាយពីមុនរួចមកហើយ អំពើបាបដែលបានចូលមកក្នុងពិភពលោក មានឥទ្ធិពលអាក្រក់លើសកលលោកទាំងមូល ធ្វើអោយអ្វីៗគ្រប់យ៉ាងលែងមានភាពល្អឥតខ្ចោះទៀត ។ ហេតុនេះហើយបានជាក្មេងៗជាច្រើន កើតមកមានរូបកាយពិការ ឬ មានរូបរាងខុសប្លែកពីធម្មតា ។

ពេលមើលឃើញបុរសខ្វាក់នោះ សាវ័ករបស់ព្រះយេស៊ូទូលសួរព្រះអង្គថា÷ *«ព្រះគ្រូ បុរសនេះកើតមកខ្វាក់ដូច្នេះ តើបណ្តាលមកពីបាបរបស់នរណា ?បាបរបស់គាត់ផ្ទាល់ ឬ បាបរបស់ឪពុកម្តាយគាត់ ? »* ព្រះយេស៊ូមានព្រះបន្ទូលតបថា÷ *«គាត់ខ្វាក់ មិនមែនមកពីបាបរបស់ឪពុកម្តាយគាត់ ឬ បាបរបស់គាត់ទេ គាត់ខ្វាក់ដូច្នេះ ដើម្បីអោយព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះអង្គ នៅក្នុងគាត់ »* (យ៉ូហាន ៩:២-៣) ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

សូមគូរបន្ទាត់ភ្ជាប់មនុស្សដែលនៅជួរទីមួយ ទៅនឹងមូលហេតុនៃទុក្ខលំបាករបស់គាត់ ដែលនៅក្នុងជួរទីពីរ (មនុស្សទីមួយ គឺលោកយ៉ូប យើងបានគូរបន្ទាត់ភ្ជាប់ហើយ ទុកជាឧទាហរណ៍) :

មនុស្សដែលមានទុក្ខលំបាក	**:គោលបំណងនៃទុក្ខលំបាក**	**:**
លោកយ៉ូប		ដើម្បីបង្ហាញទ្រានុភាពព្រះអង្គ ។
(សៅភៀវយ៉ូប)		
មនុស្សខ្វាក់		ដើម្បីល្បងលការស្មោះត្រង់ ។
(យ៉ូហាន ៩)		
លោកស្តេផាន		ដើម្បីបង្ហាញអំពើបាបរបស់គេ ។
(កិច្ចការ ៧)		
អណាញ៉ាស និង នាងសាភីរ៉ា		ដើម្បីទទួលសិរីរុងរឿងដ៏អស់កល្ប ។
(កិច្ចការ ៥)		
កូនពៅវង្វេង		ដើម្បីប្រដៅកូនដែលវង្វេង ។
(លូកា ១៥)		
លោកកូរេ		ដើម្បីបំផ្លាញមនុស្សអាក្រក់ ដែលបះបោរ ។
(ជំរឿនប្រជាជន ១៦)		

© Project WorldReach © SEAN

- អធិស្ឋានតាមរបៀបអ្នកផ្ទាល់ ដែលផុសចេញពីចិត្ត (មិនមែនគ្រប់គ្នាត្រូវតែអធិស្ឋានតាមរបៀបដូចៗគ្នានោះទេ) ។

  កំណត់សំគាល់ : យើងមិនជំទាស់នឹងវេជ្ជសាស្ត្ររបស់មនុស្សទេ ។ ព្រះជាម្ចាស់អាចប្រើវេជ្ជសាស្ត្រមនុស្ស ដើម្បីប្រោសជំងឺបានដែរ ។ សេចក្តីសំខាន់ គឺអ្នកជំងឺត្រូវចេះទុកចិត្ត និង សង្ឃឹមលើព្រះជាម្ចាស់ ។

បន្ទាប់ពីអធិស្ឋាន ត្រូវអោយជំបូន្មានដល់អ្នកជំងឺ ។

ព្រះយេស៊ូគ្រីស្តតែងតែណែនាំមនុស្ស ដែលព្រះអង្គប្រោសអោយជា ។ នៅពេលដែលព្រះអង្គបានប្រោសកូនស្រីលោកយ៉ៃរ៉ូសអោយរស់ឡើងវិញ ព្រះអង្គបង្គាប់អោយគេយកចំណីអោយនាងបរិភោគ (លូកា ៨:៥៥) ។ ព្រះអម្ចាស់មានព្រះបន្ទូលទៅអ្នកពិការ ដែលព្រះអង្គបានប្រោសឱ្យជា នៅក្បែរស្រះបេតសាថាថា÷ *«ឥឡូវនេះ អ្នកបានជាហើយ កុំប្រព្រឹត្តអំពើបាបទៀតអោយសោះ ក្រែងលោកើតការអាក្រក់ដល់អ្នកលើសមុនទៅទៀត »* (យ៉ូហាន ៥:១៤) ។ ចំពោះអ្នកដែលឈឺមិនជា យើងត្រូវបញ្ជាក់អោយគាត់ទុកចិត្តថា ព្រះជាម្ចាស់ស្រឡាញ់គាត់ និង ពន្យល់ពីមូលហេតុផ្សេងៗដែលនាំអោយមានជំងឺ (២ កូរិនថូស ១២:៧-១០) ។

ក្នុងករណីនេះ មូលហេតុនៃជំងឺ គឺភាពពិការពីកំណើត ឯការប្រោសអោយជាសះស្បើយ គឺដើម្បីថ្វាយសិរីរុងរឿងដល់ព្រះបិតានៃយើង ដែលគង់នៅស្ថានបរមសុខ ។ ពេលយើងជួបទុក្ខលំបាកម្តងៗ ព្រះជាម្ចាស់តែងតែជួយសំរាលទុក្ខ ហើយប្រទានការអត់-ធ្មត់ និង ការតស៊ូដល់អ្នក ដែលទូលសូមការទាំងនេះពីព្រះអង្គ ។



ព្រះជាម្ចាស់បង្ហាញលទ្ធផលនៃអំពើចាប តាមរយៈជំងឺ ។

ជំងឺជាច្រើនបណ្តាលមកពីអំពើបាប ពីភាពល្ងង់ខ្លៅ ឬ ពីការធ្វេសប្រហែស ។ មនុស្សខ្លះ មានជំងឺដោយសារអំពើខុសឆ្គងរបស់ខ្លួនឯងផ្ទាល់ មិនមែនដោយសារព្រះជាម្ចាស់មានព្រះហឫទ័យចង់សាកល្បងពួកគេ ឬ បង្ហាញសិរីរុងរឿងរបស់ព្រះអង្គ តាមរយៈពួកគេទេ ។



ពួកគេមិនបានយកចិត្តទុកដាក់ចំពោះសុខភាពផ្ទាល់ខ្លួន ឬ សុខភាពរបស់ក្រុមគ្រួសារខ្លួន ។

បើសិនជាបុរសនេះឈឺ តើបណ្តាលមកពីមូលហេតុអ្វី ? ។

(កិច្ចការ ៣:៦) ។ ឧទាហរណ៍ផ្សេងទៀត : ម៉ាថាយ ៨:៣ (មនុស្សឃ្លង់) យ៉ូហាន ១១:៤៣ (ការប្រោសឡាសារអោយរស់ឡើងវិញ) កិច្ចការ ៩:៣៤ (លោកអេណេ) ។ ត្រូវប្រើពាក្យបញ្ជា ដើម្បីដេញខ្មោចអោយចេញផងដែរ (ម៉ាថាយ ៨:១៦, ម៉ាកុស ១:២៥, ៥:៨, ៩:២៥) ។ ពេលដែលយើងធ្វើកិច្ចការនេះ គឺយើងបញ្ជាដោយអំណាច ដែលព្រះអម្ចាស់យេស៊ូបានប្រទានដល់យើង (ម៉ាថាយ ១០:១-៨) ។

- អធិស្ឋានបំបាក់ច្រវាក់ ដែលមារសាតាំងបណ្តាលអោយកើតមាន ហើយនឹងមានឥទ្ធិពលអាក្រក់លើក្មួនចៅរបស់ក្រុមគ្រួសារជាច្រើនជំនាន់ ។ មនុស្សប្រមឹកជាច្រើន មានឪពុកម្តាយជាអ្នកប្រមឹក ។ យើងអាចអធិស្ឋានថា÷ «ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ខ្ញុំបំបាក់ច្រវាក់នៃការញៀនស្រា ហើយរំដោះអ្នកអោយរួចពីអំពើបាបរបស់ឪពុកម្តាយអ្នក» ។ ព្រះជាម្ចាស់កាច់បំបាក់ច្រវាក់ ដែលចងពួកអ្នករងគ្រោះដោយសារការប្រមឹកស្រា កាមគុណអាសអាភាស ការស្រឡាញ់ភេទដូចគ្នា ការញៀនគ្រឿងញៀន ការញៀនថ្នាំជក់ និង ការលេងល្បែងស៊ីសង ។ល។ ។

នៅពេលដែលយើងអរព្រះគុណ និង សរសើរតម្កើងព្រះជាម្ចាស់ មុននឹងអធិស្ឋានអោយអ្នកណាម្នាក់ ព្រះជាម្ចាស់នឹងធ្វើអោយយើងកាន់តែមានជំនឿខ្លាំងឡើង ។

អធិស្ឋានដោយពាក្យសាមញ្ញ និង អធិស្ឋានអោយត្រូវនឹងសេចក្តីត្រូវការ ។

ឧទាហរណ៍ :

- សូមអធិស្ឋានទូលសូមយ៉ាងសាមញ្ញថា÷ «ព្រះជាម្ចាស់ សូមព្រះអង្គប្រោសអ៊ុំរតនៈអោយជាសះស្បើយ » ។ នៅពេលដែលព្រះយេស៊ូអធិស្ឋានអោយនរណាម្នាក់ ដែលឈឺ ព្រះយេស៊ូមានព្រះបន្ទូលខ្លីៗ (ម៉ាថាយ ៨:១-៣, ៩:២៧-២៩, ម៉ាកុស ១០:៥១-៥២) ។
- អធិស្ឋានដាក់ដៃលើ ឬក៏ពាល់អ្នកឈឺ (ម៉ាកុស ៦:៥, ម៉ាកុស ១៦:១៧-១៨, កិច្ចការ ២៨:៨) ។
- លាបប្រេងអោយគាត់ (យ៉ាកុប ៥:១៤) ។
- បញ្ជាក្នុងព្រះនាមព្រះអម្ចាស់ : *«ក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ជាអ្នកភូមិណាសារ៉ែត ចូរក្រោកឡើង ដើរទៅចុះ ! »*

យើងស្រួលដាក់ទោសមនុស្សប្រមឹកស្រា ពីព្រោះលទ្ធផលនៃកំហុសរបស់ពួកគេ មើលឃើញជាក់ស្តែង ។ ក៏ប៉ុន្តែ គ្រីស្តជនខ្លះមានទុក្ខលំបាកដែរ មិនមែនមកពីពួកគេមានទម្លាប់អាក្រក់ទេ គឺដោយសារពួកគេធ្វេសប្រហែសវិញ ។ (ឧទាហរណ៍ ការមិនលាងដៃមុននឹងរៀបចំចំអិនចំណីអាហារ ឬក៏ក្រោយពេលចេញពីបង្គន់ បណ្តាលអោយពួកគេកើតមានជំងឺ) ។ បើសិនជាពួកគេឈឺ ដោយសារមូលហេតុដូចនេះ ពួកគេមានតែបន្ទោសខ្លួនឯងប៉ុណ្ណោះ ។



© Project WorldReach © SEAN

យើងមិនត្រូវយកភាពក្រខ្សត់មកធ្វើជាលេស ដើម្បីធ្វេសប្រហែសទេ ។ យើងត្រូវថែរក្សាក្រុមគ្រួសាររបស់យើង ដូចជាផឹកទឹកស្អាត បរិភោគចំណីអាហារដែលមានជីវជាតិ រក្សាអនាម័យនៅខាងក្នុងផ្ទះ និង នៅខាងក្រៅផ្ទះ ព្រមទាំងទុកសត្វឱ្យនៅក្រៅផ្ទះ ។ល។ ។

នៅក្នុង ១ ធីម៉ូថេ ៥:៨ លោកប៉ូលមានប្រសាសន៍ថា÷ *«អ្នកណាមិនរវល់ថែទាំសាច់ញាតិរបស់ខ្លួន ជាពិសេស មិនថែទាំអ្នកដែលនៅក្នុងក្រុមគ្រួសាររបស់ខ្លួនផ្ទាល់ អ្នកនោះបានក្បត់ជំនឿរបស់ខ្លួន ហើយអាក្រក់ជាងអ្នកមិនជឿទៅទៀត »* ។

ពាក្យព្រមានខ្លាំងក្លារបស់លោកប៉ូលនេះ គឺសំរាប់ :

☐ អ្នកជឿ ។

☐ អ្នកមិនទាន់ជឿ ។

លោកប៉ូលរំលឹកអ្នកជឿអំពីភារៈកិច្ចរបស់គ្រីស្តជន ដែលត្រូវមើលថែទាំក្រុមគ្រួសាររបស់ខ្លួន មុនអ្វីៗទាំងអស់ ។

ជំវិសុទ្ធអាចបើកសំដែងប្រាប់យើងពីមូលហេតុ ដែលនាំអោយគេមានជំងឺ ។ បើសិនជាយើងមិនដឹងពីមូលហេតុទេ ក៏មិនអីដែរ យើងគ្រាន់តែអធិស្ឋានអោយគេទៅ ។

សេចក្តីសំខាន់ម្យ៉ាងទៀត គឺត្រូវអោយដឹងថា អ្នកជំងឺនោះបានទទួលការព្យាបាលត្រឹមត្រូវគ្រប់គ្រាន់ តាមវិជ្ជាពេទ្យដែរឬអត់ បើមិនបានទទួលទេ ត្រូវជួយគាត់អោយអាចទទួលបាន ។ ព្រោះវិជ្ជាពេទ្យសម័យថ្មី ក៏ជាព្រះពរមួយរបស់ព្រះជាម្ចាស់ដែរ ។

អធិស្ឋានអោយអ្នកជំងឺ ដោយជំនឿលើព្រះជាម្ចាស់ ដែលព្រោះមនុស្សឈឺអោយជា ។

ព្រះជាម្ចាស់របស់យើង ដែលពេញដោយសេចក្តីមេត្តាករុណា តែងតែជួយសំរាលទុក្ខយើង នៅពេលដែលយើងមានទុក្ខវេទនាគ្រប់បែបយ៉ាង (២ កូរិនថូស ១:៤) ។ *«ព្រះជាម្ចាស់អាចសំរេចកិច្ចការសព្វគ្រប់ទាំងអស់ដល់អ្នកជឿ »* (ម៉ាកុស ៩:២៣) ។ គឺព្រះជាម្ចាស់ជាអ្នកធ្វើកិច្ចការនេះ មិនមែនយើងទេ ។ អ្នកទាំងអស់ដែលចូលរួមធ្វើកិច្ចការនោះ ត្រូវមានជំនឿ គឺថាទាំងអ្នកដែលអធិស្ឋានអោយអ្នកឈឺ អ្នកឈឺខ្លួនឯង និង អ្នកដែលកំពុងនៅទីនោះ (ម៉ាកុស ២:៥, យ៉ូហាន ១១:២២) ។

របៀបអធិស្ឋានសំរាប់អ្នកជំងឺ

មុននឹងអធិស្ឋាន ត្រូវរកអោយឃើញឫសគល់របស់ជំងឺសិន ។

ជួនកាល ព្រះយេស៊ូនាំអ្នកជំងឺចេញពីចំណោមមនុស្សជាច្រើន ដើម្បីនិយាយជាមួយគាត់តែពីរនាក់នឹងព្រះអង្គផ្ទាល់ (ម៉ាកុស ៨:២៣) ។

យើងត្រូវសួរអ្នកជំងឺ (ឬក៏ក្រុមគ្រួសាររបស់អ្នកនោះ) អំពីបញ្ហារបស់គេ ហើយយើងខិតខំរកអោយឃើញពីមូលហេតុ ដែលជាឫសគល់របស់បញ្ហានោះ ។ យើងមិនមែនចាប់អារម្មណ៍តែលើជំងឺខាងរូបកាយប៉ុណ្ណោះទេ គឺយើងចាប់អារម្មណ៍លើតួមនុស្សទាំងមូល គឺថា លើសភាពខាងព្រលឹងវិញ្ញាណ ខាងផ្លូវចិត្ត ខាងសតិប្រាជ្ញា និង ខាងទំនាក់ទំនងក្នុងសង្គម ។

ឧទាហរណ៍ មនុស្សខ្លះឈឺ ព្រោះគេមិនទាន់អត់ទោសអោយអ្នកដែលបានធ្វើខុសមកលើគេ ។ នៅពេលដែលគេអត់ទោសអោយអ្នកនោះហើយ គេនឹងជាសះស្បើយ ។

មនុស្សខ្លះឈឺ ដោយសារមានខ្មោចចូល (ឧទាហរណ៍ ម៉ាកុស ៩:១៧-៣០) ។ ពេលយើងស្តាប់អ្នកជំងឺនិយាយ ព្រះវិញ្ញាណ-

ជួនកាល ព្រះជាម្ចាស់កែតម្រូវកូនៗរបស់ព្រះអង្គ ដែលមិនស្តាប់បង្គាប់ព្រះអង្គ តាមរយៈជំងឺ ។

មូលហេតុមួយទៀត ដែលបណ្តាលអោយមានជំងឺ គឺការដាក់ទោស ។ ព្រះជាម្ចាស់ជាព្រះបិតា ដែលស្រឡាញ់កូនៗរបស់ព្រះអង្គ វាយប្រដៅកូនៗរបស់ព្រះអង្គ នៅពេលដែលកូនៗទាំងនោះរឹងចចេស (១ កូរិនថូស ១១:៣០-៣២, ហេប្រឺ ១២:៤-១៣) ។ ព្រះជាម្ចាស់ប្រើប្រាស់ជំងឺ និង ប្រភពនៃការឈឺចាប់ផ្សេងៗ ដើម្បីវាយប្រដៅកូនៗជាទីស្រឡាញ់របស់ព្រះអង្គ ។ ព្រះអង្គវាយប្រដៅ ដើម្បីបង្កើតផលផ្លែនៃសេចក្តីសុចរិត នៅក្នុងយើង ។

ក្នុងករណីនេះ ជំងឺសំរាប់ :

☐ ធ្វើអោយយើងបានបរិសុទ្ធ ។

☐ ធ្វើអោយយើងវិនាស ។

គ្រីស្តជនណាម្នាក់ ដែលមានទុក្ខលំបាកដោយសារបានធ្វើបាបត្រូវតែកែប្រែចិត្តគំនិត និង លន់តួសារភាពអំពើបាបគ្រប់យ៉ាងរបស់ខ្លួន (យ៉ាកុប ៥:១៤-១៦) ។

ព្រះជាម្ចាស់ប្រើប្រាស់ជំងឺ និង សេចក្តីស្លាប់ដើម្បីបញ្ចប់ជីវិត បណ្តោះអាសន្ន ។

មូលហេតុមួយទៀត ដែលបណ្តាលឱ្យមានជំងឺ និង សេចក្តីស្លាប់ គឺដើម្បីឱ្យមនុស្សគ្រប់រូបអាចចេញផុតពីរូបកាយ ដែលត្រូវស្លាប់ និង រូបកាយដែលពុករលួយនេះ ។

ចំពោះមនុស្សខ្លះ ជំងឺ និង សេចក្តីស្លាប់នាំអោយបានទទួលសិរីរុងរឿងដ៏នៅអស់កល្បជានិច្ច ។ ចំពោះមនុស្សខ្លះទៀត មានន័យថា ត្រូវទៅទទួលទុក្ខទោសដ៏នៅអស់កល្ប (ម៉ាថាយ ២៥:៤៦, កាឡាទី ៦:៨) ។

ប៉ុន្តែ ចំពោះបុត្រធីតារបស់ព្រះជាម្ចាស់ ដែលស្រឡាញ់ព្រះជាម្ចាស់ យោងទៅតាម រ៉ូម ៨:២៤-២៨ ទុក្ខលំបាករបស់យើងនៅលើផែនដីនេះ មិនអាចប្រៀបធៀបនឹងសិរីរុងរឿង ដែលយើងនឹងបានទទួលនៅពេលខាងមុខបានទេ ។

ដូចនេះ យើងបានឃើញថា មានមូលហេតុច្រើនណាស់ ដែលបណ្តាលអោយមានជំងឺ និង ទុក្ខលំបាក ហើយមូលហេតុទាំងអស់នោះសុទ្ធតែកើតឡើងដោយសារមារសាតាំង និង អំពើបាប ដែលបានចូលមកក្នុងលោកីយ៍នេះ ។ ប៉ុន្តែ យើងមិនត្រូវវិនិច្ឆ័យមនុស្សឈឺទេ ព្រោះជំងឺបណ្តាលមកពីមូលហេតុផ្សេងៗ ។

បំរើមនុស្សចាស់ គឺបំរើព្រះគ្រីស្តហើយ : *«យើងសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះយើងដែរ»* (ម៉ាថាយ ២៥:៤០) ។

ជួយមនុស្សចាស់ ក៏បានន័យថា នាំគាត់អោយធ្វើកិច្ចការខ្លះ ក្នុងក្រុមជំនុំ ស្របទៅតាមសមត្ថភាពរបស់គាត់ដែរ (ដូចជា ការអធិស្ឋាន ការផ្តល់ជំបូន្មាន ការបង្រៀន និង ការធ្វើសិប្បកម្ម ។ល។) ។

យើងត្រូវបង្ហាត់បង្រៀនគ្រួសារគ្រីស្តជននិមួយៗ អោយចេះថែរក្សាមនុស្សចាស់ ដែលនៅក្នុងក្រុមគ្រួសាររបស់ខ្លួន ។ តែក្រុមជំនុំត្រូវថែរក្សាមនុស្សចាស់ដែលគ្មានក្រុមគ្រួសារថែទាំ ។ គ្មានមធ្យោបាយសំរាប់ព្យាបាលមិនអោយចាស់ជរាទេ តែយើងអាចធ្វើអោយសាច់ញាតិចាស់ទុំរបស់យើងរស់ដោយស្រួល និង ដោយសប្បាយរីករាយ ។

© Project WorldReach © SEAN

- ទៅផ្សារ ជួយទិញឥវ៉ាន់អោយគាត់
- ជូនចំណីអាហារដល់គាត់ ឬ ជួយគាត់ចំអិនអាហារ
- កាត់សក់អោយគាត់
- ច្រៀងអោយគាត់ស្តាប់
- អធិស្ឋានជាមួយគាត់
- ជួយគាត់ធ្វើកិច្ចការនៅផ្ទះ ឬ នៅក្រុមជំនុំ
- សរសេរសំបុត្រទៅគាត់
- នាំគាត់ទៅដើរលេង ឬ ទៅកំសាន្តនៅទីឆ្ងាយៗ
- លើកទឹកចិត្តគាត់អោយគូររូប ផាត់ /លាបពណ៌ ឬ ធ្វើសិប្បកម្ម
- ជូនសត្វមួយអោយគាត់ចិញ្ចឹម
- ណែនាំអោយគាត់បង្រៀនកុមារ
- ជូនអំណោយតូចៗដល់គាត់ ។

យើងត្រូវអធិស្ឋានសំរាប់អ្នកឈឺ លើកទឹកចិត្តពួកគេអោយចេះទុកចិត្តលើព្រះជាម្ចាស់ និង ទូលសូមអោយព្រះវិញ្ញាណព្រះអង្គជួយសម្រាលទុក្ខពួកគេ ។ បើសិនជាពួកគេឈឺ ដោយសារអំពើខុសឆ្គងរបស់ពួកគេផ្ទាល់ យើងត្រូវស្រឡាញ់ពួកគេ ថែមទាំងណែនាំពួកគេអោយវិលមករកព្រះជាម្ចាស់វិញ ។

ព្រះយេស៊ូបានរងទុក្ខលំបាក ដូច្នេះ ព្រះអង្គយល់អំពីទុក្ខលំបាករបស់យើង ។ ព្យាការីអេសាយទាយទុកអំពីការយាងមករបស់ព្រះគ្រីស្តថា÷ *«តាមពិត លោកបានរងទុក្ខវេទនាជំនួសយើង លោកទទួលយកការឈឺចាប់របស់យើង មកដាក់លើខ្លួនលោក ។ រីឯយើងវិញ យើងស្មានថា ព្រះជាម្ចាស់បានដាក់ទោសលោក ព្រះអង្គបានវាយ និង បន្ទាបបន្ថោកលោក»* (អេសាយ ៥៣:៤) ។



យើងមានព្រះសង្គ្រោះដែលបានដឹងពីទុក្ខលំបាក និង ការឈឺចាប់របស់យើង ព្រោះព្រះអង្គផ្ទាល់ធ្លាប់ទទួលរងទុក្ខរួចមកហើយ ។

នៅពេលដែលព្រះយេស៊ូបំពេញកិច្ចការលើផែនដី ព្រះអង្គបានរំដោះពួកអ្នកដែលជាប់ជាឈ្លើយ (លូកា ៤:១៨-១៩) ។ នៅពេលដែលព្រះអង្គសុគតលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានចាប់ផ្តើមធ្វើឱ្យអ្វីៗទាំងអស់ ប្រែក្លាយជាថ្មីវិញ (២ កូរិនថូស ៥:១៧) ។ ការនេះនឹងបានសំរេចពេញលេញ នៅពេលដែលព្រះអម្ចាស់របស់យើងយាងមកវិញ និង ស្តារអ្វីៗសព្វសារពើឡើងវិញ ហើយប្រទានអោយយើងមានរូបកាយ ដែលមិនចេះពុករលួយ ដូចព្រះកាយរបស់ព្រះអង្គផ្ទាល់ (រ៉ូម ៨:២១, ភីលីព ៣:២០-២១) ។

តើអ្នកណានៅជាមួយយើង ពេលយើងមានទុក្ខលំបាក ? ។

ដែលមានបទពិសោធន៍ក្នុងកិច្ចការនេះ ផ្តល់ដំបូន្មាន និង អធិស្ឋាន អោយពួកគេ ។

ចំពោះការជួយជាបន្តទៅទៀត សូមអានក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល ទី ៥៧ គឺ « ការឈ្នះលើភាពងងឹត » ដែលនិយាយអំពីការរំដោះមនុស្សដែលនៅក្រោមអំណាចអារក្ស) ។

យើងត្រូវយកចិត្តទុកដាក់ថែរក្សាមនុស្សចាស់ ។

មនុស្សចាស់ដែលស្តាប់មិនសូវឮ មើលមិនសូវឃើញ ឬ ពិបាកដើរទៅណាមកណា តែងតែធ្លាក់ទឹកចិត្ត ។ យើងត្រូវជួយពួកគាត់ឱ្យមានអារម្មណ៍ថា ពួកគាត់នៅមានប្រយោជន៍ និង ជួយអោយគាត់ធ្វើអ្វីដែលគាត់នៅអាចធ្វើបាន ។ ការងារស្រាលៗនឹងជួយគាត់ឱ្យមានអារម្មណ៍ថា គាត់ជាមនុស្សមានប្រយោជន៍ ពីព្រោះអ្នកឯទៀតត្រូវការគាត់ទាក់ទងនឹងគាត់ និង រាប់អានគាត់ ។

យើងអាចលើកទឹកចិត្តមនុស្សចាស់ ដោយរបៀបច្រើនយ៉ាង :

- អានព្រះគម្ពីរអោយគាត់ស្តាប់
- ស្តាប់គាត់និយាយ
- និយាយលេងជាមួយគាត់

យើងត្រូវរំដោះអ្នកជំងឺ ដែលបណ្តាលមកពីអំណាចរបស់មារសាតាំង ។

នេះជាកិច្ចការបំរើមួយ ដែលមានតែពួកគ្រីស្តជនចាស់ទុំខាងព្រលឹងវិញ្ញាណ និង មានបទពិសោធន៍ ទើបអាចធ្វើបាន ។

បើសិនជាពួកវិញ្ញាណអាក្រក់គាបសង្កត់លើអ្នកជំងឺ យើងត្រូវដេញអារក្សទាំងនោះចេញដោយអធិស្ឋាន និង តមអាហារ (ម៉ាកុស ៩:២៩) ។

យើងត្រូវបញ្ជាដេញអារក្សអោយចេញទៅ ដោយអំណាច និង ព្រះនាមព្រះយេស៊ូគ្រីស្ត ។ បើសិនជាយើងប្រឆាំងនឹងអារក្ស នោះវានឹងរត់ចេញឆ្ងាយពីយើងមិនខាន (យ៉ាកុប ៤:៧) ។ អារក្សខ្លាចពួកគ្រីស្តជន ដែលអធិស្ឋានដោយជំនឿ និង មានអំណាចរបស់ព្រះគ្រីស្ត ។ អារក្សគ្មានអំណាចស្មើនឹងព្រះគ្រីស្តទេ ព្រោះព្រះ-អង្គមានជ័យជំនះលើវា ដោយការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។

អ្នកដែលចង់រំដោះខ្លួនអោយរួចពីអារក្ស ក៏ត្រូវអនុវត្តជំនឿដែរ ។ អ្នកនោះត្រូវការមានពួកគ្រីស្តជន ដែលចាស់ទុំខាងព្រលឹងវិញ្ញាណ

របៀបផ្តល់ដំបូន្មាន និង លើកទឹកចិត្តអ្នកជំងឺ

យើងត្រូវជួយសំរាលទុក្ខអ្នកជំងឺ ដោយសេចក្តីស្រឡាញ់ ។

មនុស្សឈឺ មានការពិបាកណាស់ ដូច្នេះ ពួកគេត្រូវការឱ្យយើងជួយ និង ត្រូវការអោយយើងមានសេចក្តីស្រឡាញ់ចំពោះពួកគេ ។

យើងត្រូវទៅសួរសុខទុក្ខពួកគេ នៅកំដរពួកគេ អធិស្ឋានអោយពួកគេ និង ជួយពួកគេតាមដែលពួកគេត្រូវការ ។

យោងទៅតាម បទព្រះគម្ពីរយ៉ាកុប ១:២-៤ យើងជួយពួកគេឱ្យអាចប្រឈមមុខនឹងបញ្ហា ដោយអំណរ ។

យើងត្រូវជួយអោយអ្នកជំងឺចេះទុកចិត្តលើព្រះជាម្ចាស់ ។

ទំនុកតម្កើង ២៣ បញ្ជាក់អោយអ្នកជំងឺទុកចិត្តថា ព្រះជាម្ចាស់ជាអ្នកគង្វាលរបស់ពួកអ្នកដែលចេះទុកចិត្តព្រះអង្គ ហើយព្រះអង្គគង់នៅជាមួយអ្នកទាំងនោះ និង ការពារពួកគេ ទោះជាត្រូវឆ្លងកាត់សេចក្តីស្លាប់ក៏ដោយ ។

នៅក្នុង ម៉ាថាយ ៨:៥-១៣ ព្រះយេស៊ូប្រោសអ្នកបំរើរបស់នាយទាហានរ៉ូម៉ាំងម្នាក់អោយជាសះស្បើយ ដោយសារជំនឿរបស់នាយទាហាននោះ ។

នៅក្នុងម៉ាកុស ២:១-១២ ព្រះយេស៊ូប្រោសមនុស្សខ្វិនអោយដើរ រួច តែដំបូង ព្រះអង្គលើកលែងទោសអំពើបាបរបស់គាត់សិន ។ ដូចនេះ បើសិនជាអ្នកឈឺមិនមែនជាអ្នកជឿ ដំបូង យើងត្រូវជួយគេអោយបានសង្គ្រោះខាងព្រលឹងវិញ្ញាណសិន ។

យោងទៅតាម រ៉ូម ៨:១៦-២៨ អ្វីៗទាំងអស់ធ្វើគ្នាឡើង ដើម្បីឱ្យយើងបានទទួលផលល្អ ។

យើងត្រូវអធិស្ឋាន ទូលសុំឱ្យព្រះជាម្ចាស់ប្រោសពួកគេឱ្យជា ។

យោងទៅតាមយ៉ាកុប ៥:១៤-១៦ បើសិនជាក្នុងចំណោមបងប្អូនមាននរណាម្នាក់ឈឺ ពួកអ្នកចាស់ទុំរបស់ក្រុមជំនុំ ត្រូវទៅសួរសុខទុក្ខគាត់ លាបប្រេងអោយគាត់ និង អធិស្ឋានអោយគាត់ ។

យើងត្រូវជួយរៀបចំចិត្តគំនិតអ្នកជំងឺ ដែលជិតស្លាប់ ។

គ្រប់មនុស្សទាំងអស់ ទាំងអ្នកជឿ ទាំងអ្នកមិនជឿ សុទ្ធតែត្រូវស្លាប់ ។ បើសិនជាមានមនុស្សជិតស្លាប់ យើងត្រូវជួយលើកទឹកចិត្តពួកគេអោយពឹងលើព្រះគ្រីស្ត ។ បើសិនជាអ្នកទាំងនោះមិនមែនជាអ្នកជឿទេ យើងត្រូវខិតខំដឹកនាំពួកគេដោយទន់ភ្លន់ អោយកែប្រែចិត្តគំនិត និង ទទួលជឿលើព្រះគ្រីស្ត ។ យើងត្រូវធ្វើអោយ

ពួកគេមានអំណរ ដោយប្រាប់ថា÷ ពេលស្លាប់ទៅ គ្រីស្តជនទាំងអស់នឹងបានទៅរួមរស់ជាមួយព្រះគ្រីស្ត ។

បើសិនជាពួកគេជាអ្នកជឿ សូមអានវគ្គគម្ពីរណាមួយខាងក្រោមនេះ :

- ភីលីព ១:២១-២៣ (*«ចំពោះខ្ញុំ បើរស់ ខ្ញុំរស់រួមជាមួយព្រះគ្រីស្ត ហើយបើស្លាប់ ខ្ញុំក៏បានចំណេញដែរ »*) ។
- ១ ថេស្សាឡូនិក ៤:១៣-១៨ (*អស់អ្នកដែលជឿលើព្រះ-គ្រីស្តដែលបានស្លាប់ផុតទៅហើយ នឹងរស់ឡើងវិញ ដើម្បីស្ថិតនៅជាមួយព្រះអង្គ*) ។
- ភីលីព ៣:២០-២១ (*មាតុភូមិរបស់យើងនៅស្ថានបរម-សុខ*) ។
- ១ កូរិនថូស ១៥:៣៥-៥៨ និង ២ កូរិនថូស ៥:១ (*នៅពេលយើងរស់ឡើងវិញ យើងនឹងមានរូបកាយថ្មីដែលមិនចេះស្លាប់*) ។
- រ៉ូម ៨:៣៥ (*គ្មានអ្វីអាចបំបែកយើងចេញពីព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រីស្តបានទេ ទោះជាទុក្ខវេទនា ឬទេវទូត ឬ សេចក្តីស្លាប់ ក៏មិនអាចបំបែកយើងបានដែរ*) ។